ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកំពង់ឆ្នាំង

សំណុំរឿងព្រហ្មទណ្ឌលេខ:៥៤០

ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១៧

សាលក្រមព្រហ្មទណ្ឌ

លេខ: ១៣ (ច)

ចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ២០១៨

តាងនាមប្រជារាស្ត្រខ្មែរ

*សាលាដំបូងខេត្តកំពង់ឆ្នាំង បានបើកសវនាការ*

ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៨

*ដោយមានសមាសភាពជំនុំជម្រះ៖*

១-លោក [redacted] *ចៅក្រមជំនុំជម្រះ*

២-លោក [redacted] *តំណាងអយ្យការ*

៣-លោក [redacted] *ក្រឡាបញ្ជីសវនាការ*

*ដើម្បីធ្វើការជំនុំជម្រះលើជនជាប់ចោទ:*

១-ឈ្មោះ: [redacted] ភេទប្រុស អាយុ ៣១ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរ លក់ដូរ ទីកន្លែងកំណើតភូមិស្រែតាជ័យ ឃុំអភិវឌ្ឍន៍ ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង ទីកន្លែងសព្វថ្ងៃនៅភូមិមោស ឃុំតាំងក្រសាំង ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង ឪពុកឈ្មោះ [redacted](ស) ម្តាយឈ្មោះ [redacted]) ប្រពន្ធឈ្មោះ [redacted](រ) មានកូន ០១ នាក់ ទោសពីមុនគ្មាន (ឃុំខ្លួនថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០១៧) ។

ត្រូវជាប់ចោទពីបទ: រក្សាទុក និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិមោស ឃុំតាំងក្រសាំង ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១៧ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**អំពើប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ:**

កាលពីថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ២០១៧ វេលាម៉ោង ១៩នៅត្រង់ចំណុចស្ពានថ្មកន្ទ្រប់ព្រាល ក្នុងភូមិមោស ឃុំតាំងក្រសាំង ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង មានករណី រក្សាទុក និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ដែលបង្កឡើងដោយឈ្មោះ: [redacted] សមត្ថកិច្ចដកហូតបានវត្ថុតាង ម្សៅក្រាមសថ្លា សង្ស័យជាសារធាតុញៀនប្រភេទមេតំហ្វេតាមីន (ICE) ចំនួន០៥ កញ្ចប់ (ម្ពន់ ១.៥០ក្រាម) ទូរស័ព្ទដៃចំនួន ០១គ្រឿង ដាវចំនួន ០១ដើម និងឧបករណ៍ជក់មួយចំនួន។

បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ: ២០៨ /១៨ ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ២០១៨ របស់តំណាងអយ្យការអម សាលាដំបូងខេត្តកំពង់ឆ្នាំង ។



Scanned by CamScanner

បានឃើញ ដីកាបញ្ជូនរឿងទៅជំនុំជម្រះលេខ: ២៧ /១៨ ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ២០១៨ របស់ចៅក្រមស៊ើបសួរ។

បានឃើញ ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ: ១៨១ /១៨ ចុះថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ២០១៨ របស់ប្រធានសាលាដំបូងខេត្តកំពង់ឆ្នាំង ។

## នាពេលសវនាការ

-ចម្លើយជនជាប់ចោទឈ្មោះ: [redacted] បានឆ្លើយថា: កាលពីថ្ងៃកើតហេតុ មានឈ្មោះ: [redacted] បានទូរសព្ទមកខ្លួនកេយកគ្រឿងញៀន ដោយក្នុងនោះខ្លួន និងឈ្មោះ [redacted] បានទិញគ្រឿងញៀនរួមគ្នាចំនួន ០៥ កញ្ចប់ តម្លៃ ១០០.០០០(មួយរយពាន់)រៀល ក្នុងនោះខ្លួនបានឲ្យឈ្មោះ: [redacted] ចំនួន ០១ កញ្ចប់ ចំណែកខ្លួនបាន ចំនួន ០៤ កញ្ចប់ ខ្លួនទិញមកសម្រាប់ជក់តែម្នាក់ឯង ពុំដែលចែកចាយឲ្យទៅនរណាឡើយ ចំណែកឈ្មោះ: [redacted] ជាមិត្តភក្តិខ្លួនជាងដប់ឆ្នាំមកហើយ ខ្លួនពិតជាពុំបានជួញដូរគ្រឿងញៀនប្រាកដមែន ។

-ចម្លើយមន្ត្រីនគរបាលឈ្មោះ: [redacted] បានឆ្លើយថា: កាលពីថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ២០១៧ វេលាម៉ោង ១៩ កម្លាំងនគរបាលស្រុកទឹកផុស បានទទួលបណ្តឹងពីប្រជាពលរដ្ឋថា នៅផ្ទះរបស់ឈ្មោ[redacted]ធ្វើសកម្មភាពប្រើប្រាស់ថ្នាំញៀន និងជួញដូរថ្នាំញៀនយ៉ាងគគ្រឹកគគ្រេង ដំបូងឃាត់ខ្លួនឈ្មោ[redacted]ងឈ្មោះ: [redacted] ដោយធ្វើតេស្តទឹកនោម រកសារធាតុញៀន លទ្ធផលវិជ្ជមាន ពេលនោះក៏បានធ្វើការសាកសួរ និងឆែកឆេររកឃើញថ្នាំញៀនចំនួន ០៥កញ្ចប់តូច ដែលមានទម្ងន់ ១,៥០ក្រាម ពីឈ្មោះ: [redacted] មានដាវ ០១គ្រឿង ក្នុងនោះឈ្មោះ: [redacted] បានបញ្ជាក់ថាទិញគ្រឿងញៀនពីឈ្មោះ [redacted]

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា: មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើឈ្មោះ: [redacted] ពីបទ: រក្សាទុក និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ស្នើសូមតុលាការមេត្តាពិចារណាទៅតាមច្បាប់ ។

-ជនជាប់ចោទឈ្មោះ: [redacted] បានសំណូមពរចុងក្រោយថា: សូមឲ្យតុលាការមេត្តាបន្ធូរបន្ថយទោសដល់រូបខ្លួនផង ។

ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ
ក្រោយពីបានស្តាប់អំណានចម្លើយមន្ត្រីនគរបាលយុត្តិធម៌
ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ
ក្រោយពីបានស្តាប់សំណូមពរចុងក្រោយរបស់ជនជាប់ចោទ
ក្រោយពីបានពិនិត្យ ភស្តុតាង ឯកសារទាំងអស់ក្នុងសំណុំរឿង
ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## **សាលាដំបូងខេត្តកំពង់ឆ្នាំង យល់ឃើញថា:**

១-តុលាការបានទទួលបណ្តឹងតាមដីកាបញ្ជូនរឿងទៅជំនុំជម្រះលេខ ២៧ /១៨ ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១៨ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកំពង់ឆ្នាំង ដែលបានបញ្ជូនជនជាប់ចោទឈ្មោះ [redacted] មក



Scanned by CamScanner

តុលាការដើម្បីជំនុំជម្រះពីបទ រក្សាទុក និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិរមាស ឃុំតាំងក្រសាំង ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១៧ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២-ចម្លើយជនជាប់ចោទឈ្មោ[redacted]ថា: កាលពីថ្ងៃកើតហេតុ ខ្លួនបានទិញគ្រឿងញៀនរួមជាមួយនឹងឈ្មោ[redacted]នូន ១០០.០០០(មួយរយពាន់)រៀល ចំនួន ០៥ កញ្ចប់ ហើយចែកទៅឲ្យឈ្មោះ[redacted]ចំនួន ០១ កញ្ចប់ ចំណែកខ្លួនចំនួន ០៤ កញ្ចប់ ទុកសម្រាប់ជក់ ខ្លួនពុំដែលចែកចាយឡើយ ។

៣-ចម្លើយមន្ត្រីនគរបាលឈ្មោះ[redacted]ថា: កាលពីថ្ងៃកើតហេតុ កម្លាំងបានទទួលបណ្តឹងពីប្រជាពលរដ្ឋ ដំបូងឃាត់ខ្លួនឈ្មោះ[redacted]និងឈ្មោះ [redacted]ដោយធ្វើតេស្តទឹកនោម រកសារធាតុញៀន ក្នុងនោះឈ្មោះ[redacted]បានបញ្ជាក់ថាទិញគ្រឿងញៀនពីឈ្មោះ[redacted]ហើយពេលនោះក៏បានធ្វើការសាកសួរ និងឆែកឆេររកឃើញថ្នាំញៀនចំនួន ០៥កញ្ចប់តូច ដែលមានទម្ងន់ ១,៥០ក្រាម ពី ឈ្មោះ [redacted]មានដាវ ០១គ្រឿង។

៤-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា: មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើឈ្មោះ [redacted] ពីបទ: រក្សាទុក និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ស្នើសូមតុលាការមេត្តាពិចារណាទៅតាមច្បាប់ ។ ការប្តឹងសុំនេះតុលាការអាចពិចារណាបាន ព្រោះបើតាមអង្គហេតុ ទោះបីជាជនជាប់ចោទព្យាយាមបដិសេធ ប៉ុន្តែពេលប្រតិបត្តិការរបស់នគរបាលយុត្តិធម៌រកឃើញគ្រឿងញៀនដែលដកហូតបានពីលំនៅដ្ឋានជនជាប់ចោទ ហើយគ្រឿងញៀនចំនួនដ៏សមល្មមនេះអាចមិនគ្រាន់តែដើម្បីប្រើប្រាស់ប៉ុណ្ណោះទេ វាជាការរក្សាទុក និងជួញដូរយ៉ាងពិតប្រាកដ ។

៥-ឆ្លងកាត់សវនាការ ការពិភាក្សាដេញដោល ចម្លើយជនជាប់ចោទ ចម្លើយមន្ត្រីជំនាញ ការប្តឹងសុំរបស់តំណាងអយ្យការ ព្រមទាំងភស្តុតាងនានាក្នុងសំណុំរឿងតុលាការពិចារណាឃើញថាជនជាប់ចោទ រក្សាទុកគ្រឿងញៀន និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រាកដមែន ទោះបីជាជនជាប់ចោទព្យាយាមបដិសេធ ប៉ុន្តែពេលប្រតិបត្តិការបានដកហូតគ្រឿងញៀនមួយចំនួន ម្យ៉ាងទៀតស៊ីសង្វាក់គ្នាទៅនឹងការឆ្លើយរបស់មន្ត្រីនគរបាលថាគ្រឿងញៀនរបស់ឈ្មោះ[redacted]គឺទិញមកពីឈ្មោះ[redacted]ឬ្បីតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ។

៦-មានភស្តុតាងដាក់បន្ទុក និងពិរុទ្ធភាពគ្រប់គ្រាន់ដើម្បីផ្តន្ទាទោសជនជាប់ចោទ:

-ឈ្មោះ[redacted]ភេទប្រុស អាយុ ៣១ឆ្នាំ ។

ពីបទ:*រក្សាទុក និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន* ប្រព្រឹត្តនៅភូមិរមាស ឃុំតាំងក្រសាំង ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១៧ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។



Scanned by CamScanner

៧-វត្ថុតាងរួមមាន:

៧.១-ទូរស័ព្ទដៃចំនួន ០១ គ្រឿង គប្បីតុលាការរឹបអូសជាទ្រព្យសម្បត្តិរដ្ឋ ។

៧.២-ថ្នាំញៀនប្រភេទម៉ាទឹកកកចំនួន ០៥ កញ្ចប់ស្មើនឹង ១,៥០ ក្រាម និងឧបករណ៍ជក់មួយចំនួន គប្បីតុលាការធ្វើការរឹបអូស និងបំផ្លាញចោល ។

៨-ជនជាប់ចោទជានីតិជន ដែលមិនមានភស្តុតាងបញ្ជាក់ថាកើតមានវិបល្លាសស្មារតីទេ ដូច្នេះជននេះត្រូវតែទទួលខុសត្រូវព្រហ្មទណ្ឌ ចំពោះអំពើប្រព្រឹត្តរបស់ខ្លួន ។អំពើប្រព្រឹត្តរបស់ជនជាប់ចោទ ធ្វើឲ្យប៉ះពាល់ដល់សណ្ដាប់ធ្នាប់សាធារណៈ បំផ្លាញដល់សុខភាពខ្លួនឯងផ្ទាល់ ប៉ះពាល់ដល់ជីវភាពគ្រួសារ និងឈានដល់ការបង្កការលំបាកជាច្រើនទៀតដល់សង្គមជាតិ ដែលកើតឡើងដោយសារជាតុឥទ្ធិពលនៃគ្រឿងញៀន ។

## ហេតុដូច្នេះសម្រេច

១-ផ្ដន្ទាទោសជនជាប់ចោទ:

-ឈ្មោះ [redacted] ភេទប្រុស អាយុ ៣១ ឆ្នាំ ដាក់ពន្ធនាគារចំនួន ០៣(បី) ឆ្នាំ ។

ពីបទៈ *រក្សាទុក និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន* ប្រព្រឹត្តនៅភូមិរមាស ឃុំតាំងក្រសាំង ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១៧ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

២-វត្ថុតាងរួមមានៈទូរស័ព្ទដៃចំនួន ០១ គ្រឿង តុលាការរឹបអូសជាទ្រព្យសម្បត្តិរដ្ឋ ចំណែកថ្នាំញៀនប្រភេទម៉ាទឹកកកចំនួន ០៥ កញ្ចប់ស្មើនឹង ១,៥០ ក្រាម និងឧបករណ៍ជក់មួយចំនួន តុលាការធ្វើការរឹបអូស និងបំផ្លាញចោល ។

៣-សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី ២៧ ខែ មិនា ឆ្នាំ ២០១៨ និងប្រកាសជាសាធារណៈនៅថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៨ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ។

បើកផ្លូវប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។/.

ក្រឡាបញ្ជីសវនាការ

[redacted]

ចៅក្រមជំនុំជម្រះ

[redacted]



Scanned by CamScanner